ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិគន្ធបុប្ផាកម្ពុជា
លេខ :................ម.គ.ក........

*ថ្ងៃ អង្គារ ៦ កើត ខែ មាឃ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាបរធនបាល លើកទី ៣ នៃមូលនិធិគន្ធបុប្ផាកម្ពុជា

នៅព្រឹកថ្ងៃអង្គារ ទី ១៩ ខែ មករា ឆ្នាំ ២០២១, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃ “**មូលនិធិគន្ធបុប្ផាកម្ពុជា**” បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបរធនបាលលើកទី ៣ នៃ “**មូលនិធិគន្ធបុប្ផាកម្ពុជា**” ដោយមានវត្តមានចូលរួមពីឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈ សំខាន់ៗ ដូចខាងក្រោម÷

**១. ប្រតិបត្តិការរបស់មន្ទីរពេទ្យគន្ធបុប្ផា និងស្ថានភាពហិរញ្ញវត្ថុរបស់មូលនិធិគន្ធបុប្ផាកម្ពុជា÷**

ក្នុងឆ្នាំ ២០២០ នេះ, មន្ទីរពេទ្យគន្ធបុប្ផាបានទទួលកុមារមកពិគ្រោះ និងព្យាបាលនៅក្នុងផ្នែកពិគ្រោះជំងឺក្រៅ ចំនួន **៦៣៩ ២៦៨** ករណី, ស្ត្រីមានផ្ទៃពោះទទួលបានការពិនិត្យ និងព្យាបាលនៅផ្នែកពិគ្រោះជំងឺក្រៅផ្នែកសម្ភព ចំនួន **១៣២ ៤៤៣** ករណី, កុមារបានសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួន **១៣៣ ០២៦** នាក់, ជំងឺគ្រុនឈាមធ្ងន់ធ្ងរ ចំនួន **៤ ៤៨៨** នាក់, ជំងឺគ្រុនឈឹក ចំនួន **១ ៤៩២** នាក់, និងវះកាត់សរុបចំនួន **២៤ ៨២២** នាក់ ។

“**មូលនិធិគន្ធបុប្ផាកម្ពុជា**” បានទទួលវិភាគទានសប្បុរសធម៌សរុបចំនួនប្រមាណ **៦១ ៩៨១** (ហុកសិបមួយពាន់ ប្រាំបួនរយប៉ែតសិបមួយ) លានរៀល និង **៦ ០០០ ០០០** (ប្រាំមួយលាន) ដុល្លារអាមេរិក ក្នុងនោះ÷វិភាគទានពីរាជរដ្ឋា-ភិបាលចំនួន ៤០ (សែសិប) ប៊ីលានរៀល, ការកាត់កម្រៃពីសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ ចំនួន ២ (ពីរ) លានដុល្លារអាមេរិក, វិភាគទានពីកាកបាទក្រហម ចំនួន ១ (មួយ) លានដុល្លារអាមេរិក, និងថវិកាបរិច្ចាគពីសប្បុរសជនទូទៅចំនួនប្រមាណ ៧ ១៦៣ (ប្រាំពីរពាន់ មួយរយហុកសិបបី) លានរៀល និង ៣ (បី) លានដុល្លារអាមេរិក ។

បើប្រៀបធៀបនឹងឆ្នាំ ២០១៩, វិភាគទានទទួលបានក្នុងឆ្នាំ ២០២០ មានការថយចុះប្រមាណ ២០% (ដោយមិនរាប់បញ្ចូលថវិកាគម្រោង H.EQUIP និងការបរិច្ចាគផ្ទាល់នៅមន្ទីរពេទ្យ) ។

ថវិកាសប្បុរសធម៌នេះត្រូវបានបង្វែរជូនមន្ទីរពេទ្យគន្ធបុប្ផា តាមការស្នើសុំ និងតម្រូវការជាក់ស្តែង ។ បើគិតចាប់ពីថ្ងៃសម្ពោធ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០, “**មូលនិធិគន្ធបុប្ផាកម្ពុជា**” បានបង្វែរថវិកាជូនមន្ទីរពេទ្យគន្ធបុប្ផា បាន

ចំនួន ២៤ (ម្ភៃបួន) លានដុល្លារអាមេរិក និង ៨ (ប្រាំបី) ប៊ីលានរៀល ក្នុងនោះ សម្រាប់ឆ្នាំ ២០២០ ចំនួន ៤ (បួន) លានដុល្លារអាមេរិក (ថវិកាទទួលបានពីកាកបាទក្រហមកម្ពុជាចំនួន ១ លានដុល្លារអាមេរិក, ថវិកាទទួលបានពីគ្រឹះស្ថានអង្គរក្នុងត្រីមាសទី ៤ ឆ្នាំ ២០១៩ និងត្រីមាសទី ១, ២, និងទី ៣ ឆ្នាំ ២០២០ ចំនួនប្រមាណ ២ លានដុល្លារអាមេរិក, និងថវិកាចូលរួមសាងសង់ និងបំពាក់ឧបករណ៍នៅមន្ទីរពេទ្យជ័យវរ្ម័នទី ៧ (មន្ទីរគន្ធបុប្ផា ខេត្តសៀមរាប) ចំនួន ១ លានដុល្លារអាមេរិក) ។

**២. ការអនុវត្តសកម្មភាពរបស់មូលនិធិគន្ធបុប្ផាកម្ពុជា៖**

ក្នុងរយៈពេល ១២ ខែ នៃឆ្នាំ ២០២០ កន្លងទៅនេះ, **"មូលនិធិគន្ធបុប្ផាកម្ពុជា"** បានអនុវត្តសកម្មភាពសំខាន់ៗ រួមមាន៖ ការកៀរគរ និងទទួលការបរិច្ចាគវិភាគទានសប្បុរសធម៌, ការទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយអំពីមន្ទីរពេទ្យ និងមូលនិធិ ។

គិតត្រឹមខែ ធ្នូ ឆ្នាំ ២០២០, **"មូលនិធិគន្ធបុប្ផាកម្ពុជា"** សម្រេចបានការងារសំខាន់ៗ ដូចជា បានសហការ និងដាក់ហិបមូលនិធិនៅតាមក្រុមហ៊ុន និងទីតាំងសំខាន់ៗ សរុបចំនួន ១៦៦ ហិប, បានទទួលការផ្តល់វិភាគទានសប្បុរសធម៌ដោយផ្ទាល់ជាមួយសប្បុរសជនទាំងពីក្រសួង-ស្ថាប័នរដ្ឋ និងឯកជនជាបន្តបន្ទាប់, បានសហការ និងផលិតឃ្លីបវីដេអូខ្លីអំពីមូលនិធិគន្ធបុប្ផាកម្ពុជា និងមន្ទីរពេទ្យគន្ធបុប្ផា ចំនួន ២៤ ឃ្លីប, ទទួលបានការគាំទ្រ និងបរិច្ចាគបណ្តើៗតាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់មូលនិធិ, បានរៀបចំធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលនិធិគន្ធបុប្ផាកម្ពុជា ដែលអាចទាញយកទិន្នន័យសប្បុរសជន និងបង្កើតលិខិតថ្លែងអំណរគុណជាទម្រង់ឌីជីថល, បាន និងកំពុងរៀបចំធ្វើបច្ចុប្បន្នកម្មគេហទំព័រមូលនិធិគន្ធបុប្ផាជាមួយ និងការរចនាថ្មី, ក៏ដូចជាបានចេញសេចក្តីប្រកាសព័ត៌មានប្រចាំខែ និងត្រីមាស ជាសាធារណៈអំពីវឌ្ឍនភាពនៃមូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីបង្ហាញអំពីតម្លាភាព, បាន និងកំពុងសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ និងក្រុមហ៊ុនផ្សេងៗ សរុបចំនួន ១៣ ស្ថាប័ន ដើម្បីសម្រួលការបរិច្ចាគ ក៏ដូចជាពង្រឹង និងពង្រីកការបរិច្ចាគតាមថ្នាលឌីជីថល ជាដើម ។

ក្រុមប្រឹក្សាបរធនបាល ក៏បានពិនិត្យ ពិភាក្សា និងអនុម័តលើផែនការសកម្មភាពឆ្នាំ ២០២១ និងបានផ្តល់ការណែនាំឱ្យបន្តការបង្កើត និងពង្រីករចនាសម្ព័ន្ធទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា នៅតាមបណ្តាខេត្ត និងក្រសួង-ស្ថាប័ន ផងដែរ ។

ជាចុងបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានណែនាំឱ្យលេខាធិការដ្ឋាន **"មូលនិធិគន្ធបុប្ផាកម្ពុជា"** ខិតខំបន្ថែមទៀត ក្នុងការផ្សព្វផ្សាយដល់សាធារណជនឱ្យបានយល់ដឹងអំពីវត្តមាន និងសារៈសំខាន់នៃការបង្កើតមូលនិធិគន្ធបុប្ផាកម្ពុជានេះ ក្នុងគោលដៅកៀរគរវិភាគទានសប្បុរសធម៌ពីគ្រប់ទិសទីបន្ថែមទៀតដើម្បីបន្តរួមចំណែកទ្រទ្រង់ដល់ប្រតិបត្តិការ និងនិរន្តរភាពរបស់មន្ទីរពេទ្យគន្ធបុប្ផា និងលើកស្ទួយស្មារតី **"ខ្មែរជួយខ្មែរ"** ឱ្យបានកាន់តែទូលំទូលាយ ។